NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**អ្នកជំនាញការ អ.ស.ប ផ្នែកសិទ្ធិមនុស្ស ជម្រុញឲ្យកម្ពុជាដកការហាមធ្វើបាតុកម្ម និងអំពាវនាវឲ្យរក្សាភាពស្ងប់ស្ងាត់នៅពេលដែលមានអំពើហិង្សា**

ទីក្រុងហ្សឺណែវ (១៦ កក្កដា ២០១៤) - បន្ទាប់ពីទទួលបានសេចក្តីរាយការណ៍គួរឲ្យភ្ញាក់ពីអំពើហឹង្សាបន្ទាប់ មានបាតុកម្មរបស់គណបក្សប្រឆាំងនៅរាជធានីភ្នំពេញកាលពីម្សិលមិញនេះមក អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី បានជម្រុញដល់គ្រប់ភាគីទាំងអស់ឲ្យអនុវត្តជាបន្ទាន់នូវភាពស្ងប់ស្ងាត់ និងភាពអត់ធ្មត់បំផុត និងបានបញ្ជាក់ឡើងវិញ នូវការអំពាវនាវរបស់លោកឲ្យបញ្ឈប់ជាផ្លូវការនូវការហាមធ្វើបាតុកម្ម។

" ព្រឹត្តិការណ៍កាលពីម្សិលមិញនេះ បានបង្ហាញឲ្យឃើញពីការកាន់តែរួមតូចចង្អៀតនៃលំហលទ្ធិប្រជា ធិបតេយ្យនៅកម្ពុជា គិតចាប់ពីខែមករាមក ដែលមានផលប៉ះពាល់អវិជ្ជមានលើការអនុវត្តសិទ្ធិមនុស្សសម្រាប់ ទាំងអស់គ្នា" លោក ស៊ូប៊ែឌី បានមានប្រសាសន៍ដូច្នេះ។

អ្វីដែលបានចាប់ផ្តើមធ្វើក្នុងរូបភាពជាការតវ៉ាដោយសន្តិភាព ដឹកនាំដោយសមាជិកគណបក្សសង្គ្រោះជាតិ(CNRP) មិនបានប៉ុន្មានផង ក៏បានក្លាយទៅជាផុតឆាកនៃការប៉ះទង្គិចគ្នាអំពើហិង្សាមួយ ដែលបណ្តាលមនុស្សរហូតដល់ទៅ ៤០នាក់ ត្រូវរងរបួស ដែលក្នុងនោះភាគច្រើនគឺជាកម្លាំងសន្តិសុខឯកជន។ គិតត្រឹមពេលនេះមានបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតចំនួនប្រាំរូប និងសកម្មជនមួយរូបនៃគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន។

"ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល ឲ្យធានាការពារក្នុងការជួបប្រជុំដោយសន្តិវិធី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ដោយអនុវត្តភ្លាមៗនូវការដកការហាម ឬការរឹតបន្តឹងដែលកំពុងកើតមានលើការជួបប្រជុំគ្នា និងធានាឲ្យមានការប្រព្រឹត្តទៅប្រកបដោយមនុស្សធម៌ ទៅលើជនទាំងឡាយដែលត្រូវបានចាប់ខ្លួនដោយអនុលោមយ៉ាងម៉ឺងម៉ាត់ ចំពោះបទដ្ឋានសិទ្ធិមនុស្សស្តីពីការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌" លោកមានប្រសាសន៍សង្កត់ធ្ងន់យ៉ាងដូច្នេះ។

អ្នកជំនាញការឯករាជ្យរបស់អ.ស.ប បានជម្រុញផងដែរ ឲ្យគ្រប់ភាគីទាំងអស់ ប្រើប្រាស់មធ្យោបាយអហិង្សា ក្នុងការបញ្ចេញមតិ និងលើកកំពស់សុខសន្តិភាព និងសណ្តាប់ធ្នាប់ ក្នុងការអនុវត្តសេរីភាពរបស់ខ្លួនក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី។

"កាលពីម្សិលមិញ នៅសួនសេរីភាព ដែលជានិមិត្តរូបនៃលទ្ធិប្រជាធិបតេយ្យនៅរាជធានីភ្នំពេញ បានកើតមានជាថ្មីម្តងទៀត នូវអំពើហឹង្សា និងការប្រឆាំងជាក់ស្តែងចំពោះសេរីភាព" នេះបើតាមអ្នករាយការណ៍ពិសេសបានបញ្ជាក់។ សួនសេរីភាព ត្រូវបានបិទក្នុងខែមករា បន្ទាប់ពីអាជ្ញាធរបានចេញបញ្ជាហាមធ្វើបាតុកម្មនៅក្នុងរាជធានីភ្នំពេញ ក្រោយពីឧប្បត្តិហេតុនៃអំពើហិង្សា ក្នុងអំឡុងពេលនៃការតវ៉ាធ្វើកូដកម្ម ដោយកម្មករកាត់ដេរ។

"នៅក្នុងផលវិបាកនៃឧប្បត្តិហេតុសោកនាដកម្មនៅក្នុងសប្តាហ៍ដំបូងនៃខែមករាឆ្នាំ២០១៤ ដែលក្រោយមកមានការ ដាក់ការហាមធ្វើបាតុកម្ម នៅរាជធានីភ្នំពេញ ខ្ញុំបានក្រើនរំលឹកម្តងហើយម្តងទៀតដល់រដ្ឋាភិបាល អំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការជួយសម្រួលដល់ការធ្វើបាតុកម្មដោយសន្តិវិធី និងបានស្នើឲ្យរក្សាភាពអត់ធ្មត់បំផុតចំពោះអ្នកតវ៉ា។ ខ្ញុំ បានអំពាវនាវផងដែរដល់អ្នកដែលចូលរួមធ្វើបាតុកម្ម មិនឱ្យងាកទៅរកការប្រើអំពើហិង្សាឡើយ" អ្នកជំនាញការ អ.ស.ប បានមានប្រសាសន៍ដូច្នេះ។

នៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មចុងក្រោយរបស់លោក មកកាន់ប្រទេសកម្ពុជា លោក ស៊ូប៊ែឌី បានសម្តែងនូវកង្វល់ផងដែរ ប្រាប់ដល់រដ្ឋាភិបាល អំពីតួនាទីរបស់កម្លាំងសន្តិសុខខ័ណ្ឌ ក្នុងការគ្រប់គ្រង និងរក្សាសណ្តាប់ធ្នាប់នៃបាតុកម្មសាធារណៈ។ "ពួកគេ គឺជាបុគ្គលឯកជន ដែលទំនងជាត្រូវប្រតិបត្តិការ នៅក្រៅក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ណាមួយ ដែលមានសម្រាប់មន្ត្រីអនុវត្តច្បាប់" លោកបានព្រមានដូច្នេះ។

" ភាពអត់ធ្មត់ គឺមានសារៈសំខាន់ណាស់សម្រាប់អនាគតនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" អ្នករាយការណ៍ពិសេសមានប្រសាសន៍។ "ខ្ញុំមានការសោកស្តាយដែលថា សកម្មភាពព្យួរបដាដោយសន្តិវិធីនៅលើបន្លាលួសត្រូវបានកម្លាំងសន្តិសុខឯកជនយកដំបងវាយទៅលើក្រុមអ្នកតវ៉ា ចំណែកឯនគរបាលវិញ បែរជាឈរមើលធ្វើមិនដឹង ដែលហេតុការណ៍នេះ បាននាំទៅរកសកម្មភាពស្រដៀងគ្នាទៅនឹងអំពើហិង្សាលើហ្វូងមនុស្ស។

" លិទ្ធិប្រជាធិបតេយ្យ គឺអាស្រ័យលើការគោរពគ្នា គ្មានអំពើហិង្សា" អ្នកជំនាញការសិទ្ធិមនុស្សបានគូសបញ្ជាក់។ "ខ្ញុំអំពាវដោយពាក្យសំដីមុតមាំបំផុត សូមឲ្យគ្រប់ភាគីទាំងអស់ឲ្យធ្វើការអត់ធ្មត់" លោកបានសង្កត់ធ្ងន់។

"ទន្ទឹមនឹងអាចមានការខកចិត្តចំពោះការរឹតបន្តឹងជាបន្ត លើការជួបប្រជុំជាសាធារណៈ ក៏ដូចជាការខកចិត្តដែលចាក់ឫសគល់កាន់តែជ្រៅទៀតនោះ គួររំលឹកថា អ្នកដែលស្វែងរកការអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការជួបប្រជុំដោយសន្តិវិធី ត្រូវតែរក្សាសុខសន្តិភាព និងការគោរពសិទ្ធិមនុស្សរបស់អ្នកផ្សេងទៀត" នេះបើតាមប្រសាសន៍របស់អ្នកជំនាញការ។

អ្នករាយការណ៍ពិសេស បានជម្រុញជាថ្មីម្តងទៀត ឲ្យរដ្ឋាភិបាលកម្ពុជា ប្រកាសជាផ្លូវការអំពីការដកការហាមធ្វើបាតុកម្ម និងបញ្ជាក់ឡើងវិញ អំពីយោបល់របស់លោកថា ការរាយបន្លាលួសព័ទ្ធជុំវិញសួនសេរីភាព

មិនមានមូលហេតុណាមួយត្រឹមត្រូវនៅក្នុងច្បាប់ឡើយ។ "ការបិទសួនសេរីភាពនេះ បានធ្វើឲ្យផ្ទុះប្រតិកម្មតបថាមិនមាននរណាម្នាក់ចង់ឃើញ ហើយជាការពិតណាស់ គ្មាននរណាម្នាក់ចង់ឃើញហេតុការណ៍នេះកើតមានម្តងហើយម្តងទៀតនោះទេ" លោកបានកត់សំគាល់ដូច្នេះ។

លោក ស៊ូប៊េឌី បានសម្តែងការអាណិតអាសូរយ៉ាងខ្លាំង ចំពោះបុគ្គលគ្រប់រូប ដែលបានរងរបួសកាលពីថ្ងៃម្សិលមិញនេះ ក៏ដូចជា ចំពោះអ្នកដែលបានរងរបួស ឬស្លាប់ ក្នុងអំឡុងពេលនៃបាតុកម្ម ដែលបានកើតមាននៅក្នុងរយៈពេលនៃឆ្នាំកន្លងមកនេះ។

## ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊េឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូបនៃគណៈមេធាវីឌឹលចឹមភឹល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ីនៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្តីអាស៊ីនៃច្បាប់អន្តរជាតិ បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យខេមប្រីដជ៍។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រនេះ* http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx

(*) អ្នករាយការណ៍ពិសេសបានបញ្ជូនអនុសាសន៍របស់លោក នៅក្នុងរបាយការណ៍សំខាន់ៗចំនួនប្រាំ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយនឹងបង្ហាញរបាយការណ៍ជាបន្តបន្ទាប់ទៀត របស់លោក ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខែកញ្ញា ឆ្នាំ២០១៤ ។ សូមពិនិត្យមើលរបាយការណ៍លើកមុនៗរបស់លោក៖
http://ap.ohchr.org/documents/dpage_e.aspx?m=107

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា៖*

*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មាន** សូមទាក់ទងមក ៖ កញ្ញា អ័លហ្គា ណាកាចូ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល* onakajo@ohchr.org *ឬ សរសេរទៅកាន់* srcambodia@ohchr.org

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប ៖

សូមមេត្តាទាក់ទងមក ឈ្មោះ សាប៊ៀ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង តាមរយៈបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

**ទ្វីតធ៊ឺ៖** http://twitter.com/UNrightswire

**ហ្គោហ្គ៊ីល៖**Google+ gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire